ASIAN AMERICANS ADVANCING JUSTICE ASIAN LAW CAUCUS

ASIAN AMERICANS ADVANCING JUSTICE LOS ANGELES

## Chhoeun, et al. v. Marin, et al. ក្រុមប្រឹក្សាពិគ្រោះយោបល់សហគមន៍ ដីការបង្គាប់ហាមឃាត់មិនអោយធ្វើបណ្តោះអាសន្ន ខែមករា ឆ្នាំ ២០១៩

កាលពីថ្ងៃទី ៣ ខែមករា ឆ្នាំ២០១៩ ចៅក្រមសហព័ន្ធ បានចេញនូវដីការបង្គាប់ហាមឃាត់មិនអោយធ្វើបណ្តោះអាសន្នមួយ ទូទាំងប្រទេស ការពារ ICE កុំអោយចាប់ឃុំខ្លួនឡើងវិញដល់ជនភៀសខ្លួនកម្ពុជាភាគច្រើន ដែលមានដីការបង្គាប់បញ្ជាសំរេចចុងក្រោយអោយធ្វើនិរទេស ដោយគ្មានការផ្តល់នូវសេចក្តីជូនដំណឹងជាមុន នោះឡើយ។

<u>តើខ្ញុំបានត្រូវដាក់បញ្ចូល ក្នុងដីការបង្គាប់ហាមឃាត់មិនអោយធ្វើបណ្តោះអាសន្ន ឬទេ?</u>
បណ្តឹងជាក្រុមនេះ (Chhoeun) រួមបញ្ចូល នូវរាល់ជនជាតិកម្ពុជាទាំងអស់ ដែលនៅក្នុងសហរដ្ឋអាមេរិក ដែលមាន ឬកំពុងជាប់នូវដីការបង្គាប់បញ្ជាសំរេចចុងក្រោយ អោយធ្វើនិរទេស ឬជនដែលត្រូវដកយកចេញ ដែលបានត្រូវដោះលែងចេញពីមន្ទីរឃុំឃាំងអន្តោប្រវេសន៍ ហើយមិនត្រូវបានផ្តន្ទាទោស ជាបន្តបន្ទាប់ពីបទឧក្រិដ្ឋណាមួយ ឬខកខានមិនបានបង្ហាញខ្លួនជាមួយ ICE។

ប្រសិនបើអ្នក មិនប្រាកដថាតើអ្នកបានត្រូវដាក់បញ្ចូល ក្នុងដីការបង្គាប់ហាមឃាត់មិនអោយធ្វើបណ្តោះអាសន្នទេនោះ ហើយអ្នកមានឈ្មោះ ត្រូវបង្ហាញខ្លួន ក្នុងខែមករា ឆ្នាំ២០១៩, សូមទូរស័ព្ទមកកាន់យើងខ្ញុំ តាមលេខ 415-952-0413។ ប្រសិនបើ អាស័យដ្ឋានរបស់អ្នកមិនទាន់សម័យជាមួយនិង ICE ទេនោះ ឬអ្នកខកខានមិនបានទៅបង្ហាញខ្លួន, អ្នកអាចនិង មិនបានទទួលនូវសេចក្តីជូនដំណឹងដែលតំរូវដោយដីការបង្គាប់ហាមឃាត់មិនអោយធ្វើបណ្តោះអាសន្ន នេះឡើយ។

<u>តើដីការបង្គាប់ហាមឃាត់មិនអោយធ្វើបណ្តោះអាសន្ន មានសុពលភាពយូរប៉ុណ្ណា?</u>
ដីការបង្គាប់ហាមឃាត់មិនអោយធ្វើបណ្តោះអាសន្ន និងនៅតែចូលជាធរមាន ឬនិងនៅតែមានសុពលភាព រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩។ ចៅក្រមនិងធ្វើសវនាការ ដើម្បីសំរេចថា តើនិងត្រូវធ្វើអ្វីបន្តទៅទៀត បន្ទាប់ពីថ្ងៃនោះ។

<u>តើដីការបង្គាប់ហាមឃាត់មិនអោយធ្វើបណ្តោះអាសន្នធ្វើអ្វីខ្លះ និងតើវាមិនធ្វើអ្វីខ្លះ?</u>
ដីការបង្គាប់ហាមឃាត់មិនអោយធ្វើបណ្តោះអាសន្ន មិនការពារអោយ ICE ក្នុងការចាប់មនុស្សនោះឡើយ។ វាធ្វើការការពារ ICE ក្នុងការចាប់មនុស្ស ដែលរួមបញ្ចូលក្នុងបណ្តឹងជាក្រុមនេះ លើកលែងតែពួកគេផ្តល់នូវសេចក្តីជូនដំណឹង ជាលាយលក្ខ័ណ៍អក្សរក្នុងរយៈពេល ១៤ ថ្ងៃ ជាមុន ដែលថាពួកគេមានគម្រោងនិងចាប់ជនណាម្នាក់និងផ្តល់អោយពួកគេទាំងនោះ នូវឯកសារចោទប្រកាន់នានាពីតុលាការអន្តោប្រវេសន៍របស់ពួកគេ, ដីការបង្គាប់អោយដកយកចេញ, និងកំណត់ត្រានានា អំពីការផ្តន្ទាទោសនៃបទឧក្រិដ្ឋទាំងឡាយនោះ (ដើម្បីអោយពួកគេអាចពិភាក្សា ឬទទួលប្រឹក្សាយោបល់ជាមួយ និងមេធាវីអន្តោប្រវេសន៍ ស្តីអំពីថាតើពួកគេអាចនិងត្រូវ ឬមានលទ្ធភាពក្នុងការបើកករណីរបស់ពួកគេ ជាថ្មីឡើងវិញ និងដើម្បីលុបចោល/បដិសេធចោល នូវដីការបង្គាប់អោយដកយកចេញ)។

ផងដែរ ដីការបង្គាប់ហាមឃាត់មិនអោយធ្វើបណ្តោះអាសន្ន មិនការពារអោយ ICE ក្នុងការធ្វើនិរទេសប្រជាជននោះទេ ទោះបីជាពួកគេបានត្រូវចាប់ឃុំខ្លួនសារឡើងវិញ ដោយមិនមាននូវសេចក្តីជូនដំណឹងក៏ដោយ។ ជនភៀសខ្លួនកម្ពុជាទាំងឡាយ ដែលនៅក្នុងមន្ទីរឃុំឃាំង ត្រូវតែធ្វើសកម្មភាពអោយបានយ៉ាងឆាប់ហ័សជាទីបំផុត ដើម្បីបន្តស្វែងរកនូវជំនួយអន្តោប្រវេសន៍ ដើម្បីចៀសវាង ឬគេចអោយផុត ពីការធ្វើនិរទេស។

<u>តើខ្ញុំនិងត្រូវធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំមានការណាត់ជួបបង្ហាញខ្លួនជាមួយ ICE នាពេលខាងមុខនេះ?</u>
ទូរស័ព្ទទៅកាន់ហាតឡាញផ្នក់ចូល ឬផ្នក់ឆែកឆេរ (raid hotline) តាមលេខ 415-952-0413 ដើម្បីនិយាយជាមួយមេធាវី។